Sipar

Save the Children

# វិធីសាស្ត្រ

# ផលិតសៀវភៅកុមារតូច



សៀវភៅនេះផលិតឡើងក្នុងគោលបំណងផ្តល់គន្លឹះសំខាន់ខ្លះៗ
ដល់អ្នកដែលមានបំណងចង់ផលិតសៀវភៅសម្រាប់កុមារតូចៗ

Save the Children first read PRUDENCE FOUNDATION

កម្មវិធីអំណានដំបូងគាំទ្រក្រុមគ្រួសារកុមារតូចៗឱ្យរៀនជាមួយកូនៗ កម្មវិធីនេះលើកទឹកចិត្តឪពុកម្តាយ និងអ្នកមើលថែកុមារឱ្យនិយាយ ច្រៀង រាប់ចំនួន និងអានសៀវភៅជាមួយកូនៗ

កម្មវិធីនេះក៏បានជួយពង្រឹងសមត្ថភាពរបស់អ្នកបោះពុម្ពផ្សាយសៀវភៅ អ្នកនិពន្ធ និងវិចិត្រករ ឬអ្នករចនារូបភាពក្នុងស្រុកដើម្បីផលិត បោះពុម្ពផ្សាយសៀវភៅសម្រាប់កុមារតូចជាភាសាជាតិឱ្យកាន់តែសម្បូរបែបនិងប្រកបដោយគុណភាព។ កម្មវិធីអំណានដំបូងទិញសៀវភៅ ពីអ្នកបោះពុម្ពផ្សាយសម្រាប់ចែកជូនដោយឥតគិតថ្លៃទៅដល់ក្រុមគ្រួសារកុមារតូចៗ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលអប់រំឪពុកម្តាយរបស់កម្មវិធីនេះ។ អ្នកបោះពុម្ពផ្សាយសៀវភៅត្រូវបានលើកទឹកចិត្តឱ្យចែកចាយសៀវភៅទាំងនោះនៅលើទីផ្សារក្នុងស្រុកផងដែរ ដើម្បីឱ្យគ្រួសារដទៃទៀតដែលមិនបានចូលរួមជាមួយកម្មវិធីអាចរកទិញសៀវភៅទាំងនោះសម្រាប់កូនៗរបស់ពួកគេ។ អង្គការSave the Children និងមូលនិធិព្រូដិនស៍មិនទទួលបានប្រាក់កម្រៃ ឬប្រាក់ចំណូលពីការលក់សៀវភៅកុមារតូចទាំងនេះនៅលើទីផ្សារនោះទេ។

កម្មវិធីអំណានដំបូងបានកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជាដោយអង្គការSave the Children ដែលជាអង្គការឯករាជ្យដ៏ធំបំផុតលើពិភពលោកធ្វើការដើម្បីកុមារដោយទទួលបានការឧបត្ថម្ភថវិកាពីមូលនិធិព្រូដិនស៍។ មូលនិធិព្រូដិនស៍ដែលគាំទ្រលើវិស័យអប់រំកុមារ និងការត្រៀមបម្រុងទប់ស្កាត់គ្រោះមហន្តរាយ និងការស្តារឡើងវិញ គឺជាមូលនិធិសប្បុរសធម៌របស់ក្រុមហ៊ុនPrudential Corporation Asia ។

First Read supports families with young children to learn together. It encourages parents and carers to talk, sing, count and read books with their children.

First Read also works to improve the abilities of local publishers, authors, and illustrators to publish high quality, local language books for young children. First Read purchases these books from publishers and gifts them to families participating in the parenting education sessions which form party of the project. Publishers are also encouraged to make the books available for sale in the local market so that other families can benefit from them. Neither Save the Children nor Prudence Foundation receives any proceeds from the sale of these books.

First Read is being implemented in Cambodia by Save the Children, the world's leading independent organisation for children and is being funded by Prudence Foundation. Prudence Foundation supports children, education, and disaster preparedness & recovery and is the charitable arm of Prudential Corporation Asia.

# វិធីសាស្ត្រ

# ផលិត

## សៀវភៅកុមារតូច

# មាតិកា

## I. ការអភិវឌ្ឍកុមារតូច

- មូលដ្ឋាននៃការលូតលាស់របស់កុមារតូច
- ភាពចាំបាច់របស់សៀវភៅសម្រាប់កុមារតូច
- ចំណេះដឹងមូលដ្ឋាន អំពីការរៀនអក្សរដែលកុមារតូច នឹងទទួលបានពីការប្រើប្រាស់សៀវភៅ



## II. សៀវភៅសម្រាប់កុមារតូច

- ការកំណត់តាមកម្រិតអាយុ
- ការបែងចែកតាមប្រភេទសៀវភៅ
- ការបែងចែកតាមកម្រិតភាសា
- ការបែងចែកតាមចំណង់ចំណូលចិត្ត



## III. ការផលិតសៀវភៅកុមារតូច

- ការនិពន្ធ
- ការបង្កើតរូបភាព
- ការបោះពុម្ព
- ការបង្កើតសៀវភៅដោយដៃ



## IV. មុខងារផ្សេងៗក្នុងវិស័យសៀវភៅកុមារតូច

- តួនាទីអ្នកធ្វើការលើវិស័យសៀវភៅ
- ទំនាក់ទំនងរវាងអ្នកបោះពុម្ពផ្សាយ អ្នកនិពន្ធ អ្នកគំនូរ
- ការធ្វើតេស្ត
- ការគ្រប់គ្រងលើចំណាយ
- ការចែកចាយ និងការគ្រប់គ្រងស្តុក
- ជីវិតថ្មីរបស់សៀវភៅ



# ការអភិវឌ្ឍកុមារតូច



*ការអភិវឌ្ឍកុមារតូច ជាដំណាក់កាលលូតលាស់ដែលកុមារតូចត្រូវឆ្លងកាត់ទៅតាមដំណាក់កាលអាយុ រួមមានការរៀនអង្គុយ រៀនដើរ រៀននិយាយជាដើម។ នៅប្រទេសកម្ពុជា កុមារតូចត្រូវបានគេកំណត់អាយុចាប់ពី០ ដល់ក្រោម៦ឆ្នាំ។ នៅប្រទេសខ្លះគេកំណត់ពី០ ដល់ក្រោម៨ឆ្នាំ។ ការសិក្សាស្រាវជ្រាវបង្ហាញថា ការរីកចម្រើននៃញាណផ្សេងៗមានកម្រិតខ្ពស់បំផុតនៅកំឡុងវ័យដំបូងរបស់កុមារ ជាពិសេសពី០ ទៅក្រោម៦ឆ្នាំ។ អាហារូបត្ថម្ភគ្រប់គ្រាន់ផ្តល់នូវការលូតលាស់ផ្នែករាងកាយ ប្រាជ្ញាស្មារតី និងបំណិនផ្សេងៗ ផ្តល់ការលូតលាស់ផ្នែកអារម្មណ៍ និងសតិបញ្ញាក្មេងដែរ។ កុមារដែលទទួលបានបំណិនល្អៗនៃការអភិវឌ្ឍតាំងពីតូច ភាគច្រើនដឹងពីរបៀបនៃការរៀន មានភាពងាយស្រួលក្នុងការចាប់យកចំណេះដឹងផ្សេងៗនៅពេលគេធំឡើង។ កុមារខ្លះអាចមានបំណិននៃការរៀនតាំងពីធម្មជាតិ និងខ្លះ ទៀតអាចអភិវឌ្ឍតាមរយៈការផ្តល់ឱ្យរបស់អ្នកមើលថែ និងបរិយាកាសជុំវិញ។*

## ១. មូលដ្ឋាននៃការលូតលាស់របស់កុមារតូច

| **អាយុ** | **ការអភិវឌ្ឍ** | | | | | |
|---|---|---|---|---|---|---|
| | **ការញ៉ាំ** | **ចលនាតូច** | **ចលនាធំ** | **ភាសា** | **បញ្ញាការគិត** | **សង្គមអារម្មណ៍ សីលធម៌ វប្បធម៌** |
| **ពីកើតដល់៦ខែ**  | បៅទឹកដោះម្តាយតែមួយមុខគត់ | ចាប់កាន់វត្ថុដែលនៅជិតដៃ | ងើបក្បាលរយៈពេលខ្លី | បញ្ចេញសំឡេង (កកែកករ) | ស្វែងយល់ពីវត្ថុផ្សេងៗ តាមរយៈការឃើញ សំឡេង អារម្មណ៍ និងការចាប់ដាក់មាត់ | សើច ឬញញឹម ពេលមានគេប្រឡែង |
| **ពី៦ដល់៩ខែ**  | ផឹកទឹកនឹងពែង ឬកែវបាន | ស្វែងរកវត្ថុផ្សេងៗ | ចាប់ផ្តើមអង្គុយ និងវារលូន | បញ្ចេញសំឡេងឆ្លើយតបនឹងសូរសំឡេង | ធ្វើត្រាប់តាមសកម្មភាពកាយវិការ ដូចជាទះដៃ ចាប់ចាបងីងើ | លេងល្បែងងាយៗ ដូចជាវូមវ:អ៊ី |
| **ពី៩ដល់១២ខែ**  | ញ៉ាំអាហារទន់លាយរឹងដោយស្លាបព្រា | ចាប់កាន់វត្ថុដោយម្រាមដៃ | ចាប់ផ្តើមចេះតោង | និយាយត្រាប់តាម | ចាប់កាន់ និងទទួលយក | លេងជាមួយកុមារដទៃ |

| អាយុ | ការញ៉ាំ | ចលនាតូច | ចលនាធំ | ភាសា | បញ្ញាការគិត | សង្គមអារម្មណ៍ សីលធម៌ វប្បធម៌ |
|---|---|---|---|---|---|---|
| **ពី១ដល់២ឆ្នាំ**  | ចូលរួមញ៉ាំអាហារជាមួយសមាជិកគ្រួសារ | ចាប់គូសវាស | ចាប់ផ្ដើម ចេះដើរ | និយាយពាក្យងាយៗ និងប្រើពាក្យផ្សំ | ឆ្ងល់ និងរកហេតុផល | ចេះជួយធ្វើការងារផ្ទះងាយៗ |
| **ពី២ដល់៣ឆ្នាំ**  | ញ៉ាំអាហារបានបរិមាណ ១/៣ ឬ១/២ នៃមនុស្សធំ | ចាប់គូសវាសជារាងផ្សេងៗ និងផាត់ពណ៌ | រត់ និងលោត | និយាយបានច្បាស់ និងយល់ពីអត្ថន័យនៃការសន្ទនា | ញែក ឬចែកក្រុមវត្ថុតាមរយៈពណ៌ រាង ធាតុ ។ល។ | អាចប្រាប់បានថាខ្លួនឯងឈ្មោះអ្វី ប្រុស ឬស្រី ហើយធ្វើអ្វីមួយដោយខ្លួនឯង |
| ពី៣ដល់ក្រោម៦ឆ្នាំ   | ជួយរៀបចំម្ហូបអាហារ | គូរគំនូរជារូប និងផាត់ពណ៌ | បោះ គប់ តោងឡើង | ចេះសួរហេតុអ្វី និងអាចប្រាប់រឿងរ៉ាវផ្សេងៗ | ចាប់ផ្ដើមស្វែងយល់ពីពិភពខាងក្រៅ | លេងល្បែងជាក្រុម |

## ២. ភាពចាំបាច់របស់សៀវភៅសម្រាប់កុមារតូច

ក្រៅពីបំណិននៃការរៀន កុមារទទួលបាននូវបំណិននៃការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។ វាជាការសំខាន់ដែលនិយាយ ឬអានសៀវភៅជាមួយកុមារតូចទោះជាគេមិនទាន់ចេះនិយាយក៏ដោយ ព្រោះខួរក្បាលពួកគេចាប់ផ្ដើមដំណើរការដោយចងចាំពាក្យទាំងអស់នោះ។ លើសពីនេះ សៀវភៅកសាងក្ដីស្រលាញ់រវាងកុមារ និងមនុស្សធំ តាមរយៈការផ្លាស់ប្ដូរសំណួរចម្លើយផ្សេងៗ ។

កុមារមានទម្លាប់ចូលចិត្តអានសៀវភៅ គឺភាគច្រើនដោយសារពួកគេទទួលនូវការបណ្ដុះទម្លាប់នេះតាំងពីតូចតាមរយៈឪពុកម្ដាយ ឬអ្នកថែទាំ។ ប្រសិនបើការអានសៀវភៅ ធ្វើឱ្យពួកគេមានអារម្មណ៍សប្បាយចិត្ត ពួកគេនឹងបន្តទម្លាប់នៃការអាននេះពេញមួយជីវិតរបស់ពួកគេ។ ដូច្នេះវាជាការសំខាន់ក្នុងការនាំកុមារឱ្យ

ស្វែងយល់ពីសៀវភៅ តាមរយៈការអានសៀវភៅឱ្យកុមារស្ដាប់ ដើម្បីបណ្ដុះទម្លាប់ឱ្យកុមាររៀនសង្កេតលើតួអក្សរ សញ្ញា ពាក្យ ឬរូបភាពផ្សេងៗនៅជុំវិញខ្លួនគេ។

## ៣. ចំណេះដឹងមូលដ្ឋានរបស់កុមារតូចលើការអាន និងសរសេរ តាមរយៈការប្រើប្រាស់សៀវភៅ

បន្ថែមពីលើនេះ តាមទ្រឹស្ដី ឬបទពិសោធន៍របស់អ្នកជំនាញអប់រំកុមារតូចរបស់អង្គការSave the Children បានឱ្យដឹងថា កុមារតូចមានចំណេះដឹង និងបំណិនមូលដ្ឋានអំពីការរៀនអាន និងសរសេរ គឺនៅពេលដែលពួកគេ ៖

- មានសមត្ថភាពយល់ និងប្រើប្រាស់ភាសាតាមរយៈការស្ដាប់ និយាយ និងចាប់យក ឬរៀនពីពាក្យថ្មីៗ។
- មានសមត្ថភាពយល់ពីគោលបំណង និងអត្ថន័យនៃសញ្ញាខ្លីៗ (អក្សរ  ពាក្យ រូបភាព) និងអត្ថបទ។ គេយល់ទំនាក់ទំនងពីទំព័រមួយទៅទំព័រមួយ និងយល់ថាមានការចាប់ផ្ដើម និងបញ្ចប់។
- មានសមត្ថភាពយល់ពីអ្វីទៅហៅថាសៀវភៅ និងរបៀបប្រើប្រាស់ ឬអានសៀវភៅតាមរយៈរូបភាព។
- មានសមត្ថភាពអាចសម្គាល់ និងនិយាយពីឈ្មោះតួអក្សរដែលមានក្នុងភាសាណាមួយ។ បំណិននេះជាគ្រឹះជួយឱ្យកុមារមានចំណេះដឹងអំពីការបញ្ចេញសំឡេងទៅតាមតួអក្សរ។
- មានសមត្ថភាពអាចសម្គាល់តួអក្សរ និងបញ្ចេញសំឡេង ៖ យល់អំពីបន្សំនៃសំឡេងតួអក្សរច្រើនបង្កើតបានជាពាក្យថ្មីមួយ។ ឧទាហរណ៍ អក្សរ «ក» បញ្ចេញ សំឡេង«ក» ហើយ ស្រៈ «ា»  បញ្ចេញសំឡេង «អា» នៅពេលសំឡេង «ក» ផ្សំជាមួយសំឡេង «អា» បង្កើតបានជាពាក្យថ្មី ដែលបញ្ចេញសំឡេង «កា»។







# សៀវភៅសម្រាប់កុមារតូច



មុននឹងចាប់ផ្ដើមផលិតសៀវភៅកុមារតូច យើងគួរស្វែងយល់ពីលក្ខណៈរបស់ក្រុមសៀវភៅកុមារតូច ៖ ការបែងចែកទៅតាមប្រភេទ កម្រិតអាយុ កម្រិតភាសា និងចំណង់ចំណូលចិត្តរបស់កុមារ។ វាជាគំនិតជំនួយសំខាន់សម្រាប់អ្នកមាន បំណងចង់ផលិតសៀវភៅ ព្រោះផ្នែកនីមួយៗផ្ដល់គន្លឹះខ្លះៗ អំពីប្រភេទសម្ភារៈក្នុងការផលិតសៀវភៅ ពីរូបភាព ពីប្រធានបទ ក៏ដូចជាអត្ថបទ។

## ១. ការកំណត់តាមកម្រិតអាយុ

គេសម្គាល់សៀវភៅកុមារតូចដោយសាររូបរាងខាងក្រៅ និងការរចនាខាងក្នុង។ ការធ្វើសៀវភៅតាមកម្រិតអាយុរបស់កុមារ នឹងជួយឱ្យកុមារដែលបានប្រើសៀវភៅនោះអភិវឌ្ឍផ្នែកបញ្ញាបានល្អ។ យើងអាចប្រៀបធៀបទៅនឹងការផលិតសម្លៀកបំពាក់ ឱ្យត្រូវទំហំរបស់អ្នកប្រើ។ ដូច្នេះហើយការផ្ដល់សៀវភៅមនុស្សធំដល់កុមារតូចមិនត្រឹមតែមិនផ្ដល់ផលអ្វីដល់ពួកគេទេ ប៉ុន្តែវាថែមទាំងធ្វើឱ្យពួកគេធុញទ្រាន់ជាមួយសៀវភៅទៀតផង។

### ពីកើតដល់១៨ខែ

- ✔ សៀវភៅធ្វើពីក្រដាសកាតុង ក្រណាត់ ធន់នឹងការប្រើប្រាស់របស់កុមារតូច
- ✔ រូបភាពងាយៗ ច្បាស់ មិនសាំញ៉ាំ ពណ៌ស្រស់ឆើត
- ✔ ប្រធានបទសាមញ្ញ ទាក់ទងនឹងមនុស្ស សត្វ វត្ថុដែលនៅជុំវិញកុមារតូច។ ឧទាហរណ៍ រូបភាពក្រុមគ្រួសារ ដងខ្លួនទារក សត្វនៅជុំវិញខ្លួន សម្លៀកបំពាក់ ។ល។
- ✔ ខ្លឹមសារមានគោលបំណងអភិវឌ្ឍបំណិនក្នុងការនិយាយរបស់កុមារតូច
- ✔ អត្ថបទគួរតែសាមញ្ញ ងាយៗ មានពាក្យជួននិងច្រំដែល។

## ពី១៨ខែ ដល់៣ឆ្នាំ

✔ ផ្ទៃសៀវភៅសំខាន់សម្រាប់ឱ្យកុមារស្ទាប ប៉ះ ឬលេង។ ឧទាហរណ៍ បើសៀវភៅនិយាយអំពីសត្វ គេដេរក្រណាត់ដូចរោមសត្វដើម្បីឱ្យកុមារស្ទាប។

✔ រាងសៀវភៅដូចប្រធានបទរឿង។ ឧទាហរណ៍ បើសៀវភៅនិយាយអំពីសត្វគោ គេកាត់រាងវាដូចសត្វគោ។

✔ មានលក្ខណៈពញ្ញាក់អារម្មណ៍។ ឧទាហរណ៍ សៀវភៅ«ខ្ញុំជានរណា?»

✔ ខ្លឹមសារបណ្តុះភាសានិយាយ និងចាប់ផ្តើមឈានទៅផ្តល់ចំណេះដឹងអំពីសញ្ញាណ និងទម្លាប់ល្អងាយៗ។

ឧទាហរណ៍ សៀវភៅពាក្យផ្ទុយ ការប្រៀបធៀបរូបរាង ការរាប់ចំនួន ការរៀននិយាយជម្រាបសួរ អរគុណ...

✔ អត្ថបទគួរតែសាមញ្ញ ងាយៗ មានពាក្យជួន និងច្រំដែល។



## ពីអាយុ៣ឆ្នាំ ដល់៥ឆ្នាំ

- ខ្លឹមសារមានគោលបំណងដើម្បីលើកទឹកចិត្តការរៀនដំបូងរបស់កុមារតូច (ឧទាហរណ៍ សៀវភៅនិយាយអំពីការទៅរៀនថ្ងៃដំបូង ឬផ្តល់បំណិនបុរេគណិត (ឧទាហរណ៍ រៀនចំនួន និងលេខ ឬផ្តល់បំណិនបុរេសំណេរ (ឧទាហរណ៍ ស្គាល់តួអក្សរ តាមរយៈរូបភាព និងស្នាមចុចឱ្យកុមារគូរតាម)
- បង្ហាញពីពណ៌ លេខ មធ្យោបាយធ្វើដំណើរ សត្វ ពេលវេលា ។ល។
- សៀវភៅហ្វឹកហាត់ (ឧទាហរណ៍ សម្រាប់គូរ ភ្ជាប់រូប ផាត់ពណ៌)
- រូបពិតអាចជំនួសគំនូរ។



# ៣. ការបែងចែកតាមប្រភេទសៀវភៅ

គេបែងចែកសៀវភៅកុមារតូចជាច្រើនប្រភេទដូចជា ៖

### កម្រងរូបភាព

គឺជាសៀវភៅរូបភាពអំពីឈ្មោះវត្ថុផ្សេងៗ។ ឧទាហរណ៍ សៀវភៅរូបថត រូបគំនូរ សៀវភៅរូបភាព។ល។



### សញ្ញាណ

គឺជាសៀវភៅដែលផ្តល់សញ្ញាណដំបូងដល់កុមារ។ ឧទាហរណ៍ អក្សរ លេខ រាង ពណ៌ ពាក្យផ្ទុយ ពាក្យប្រៀបធៀប រៀនពាក្យ សំឡេង។ល។



### អាថ៌កំបាំង

គឺជាសៀវភៅដែលមានលាក់រូបភាពខាងក្នុង ឬផ្ទៃប្លែកៗ សម្រាប់ឱ្យកុមារប៉ះ ឬស្ទាប។ វាមានតួនាទីជួយការគិតរំញោច អភិវឌ្ឍកាយវិញ្ញាណរបស់កុមារតូចៗ។ ឧទាហរណ៍ សៀវភៅអាថ៌កំបាំង ជើងនរណា? នរណាលាក់ខ្លួន? សៀវភៅមានចោះប្រហោងដើម្បីឱ្យកុមារលេង ។ល។



## សៀវភៅហ្វឹកហាត់

គឺជាសៀវភៅដែលជួយឱ្យកុមារតូចបណ្ដុះគំនិតច្នៃប្រឌិត
និងអភិវឌ្ឍចលករតូចដែលជាមូលដ្ឋានគ្រឹះក្នុងការសរសេរ
ដោយដៃ។ ឧទាហរណ៍ សៀវភៅផ្គូរផ្គង គូសភ្ជាប់ រករូបខុស
គូរគំនូសងាយៗ ការផាត់ពណ៌ បែងចែករវាងរូបរាង
និងពណ៌។ល។



## ពាក្យជូនរណ្ដំ

គឺជាសៀវភៅមានអត្ថបទសាមញ្ញ ជូនរណ្ដំ សូរងាយ
ងាយនិយាយ ស្រួលស្ដាប់។  វាមានតួនាទីអភិវឌ្ឍភាសា
ការស្ដាប់ បម្រុងប្រយ័ត្ន និងរាងកាយរបស់កុមារ។ ឧទាហរណ៍
កំណាព្យ មេសូត្រ ពាក្យកម្រងកែវ ចម្រៀង។ល។



## រឿង

គឺជាសៀវភៅរូបភាពដែលរៀបរាប់ពីសកម្មភាពតាមរយៈតួអង្គ
(មនុស្ស សត្វ វត្ថុ...)។ ឧទាហរណ៍ រឿងនិទាន រឿងព្រេង
រឿងទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ការស្រឡាញ់របស់ឪពុក
ម្ដាយនិងកូន រឿងបែបកម្សាន្ត បែបផ្សងព្រេង របៀន
បទពិសោធន៍លើកដំបូង ផ្ដល់ដំបូន្មាន បាតុភូតធម្មជាតិ។ល។



# ៤. ការបែងចែកតាមកម្រិតភាសា

*ភាសារបស់កុមារតូចនៅមានកម្រិត ដូច្នេះការប្រើប្រាស់ពាក្យពេចន៍ក្នុងសៀវភៅត្រូវឱ្យស្របតាមចំណេះដឹងរបស់ពួកគេ។*

*ការរៀនភាសាមានបីដំណាក់កាល*

**១**

***សម្រាប់រៀននិយាយ៖***
*រីករាយក្នុងការអានជាមួយគ្នា ដោយការបង្ហាញរូបភាព និងនិយាយអំពីរូបភាព ចេះរបៀបបើកសៀវភៅមើល។*

**២**

***រៀនផ្គូរផ្គង សំឡេង និងអក្សរ៖***
*សៀវភៅព្យញ្ជនៈ ផ្តោតលើអក្សរ សៀវភៅពាក្យស្ទួន ផ្តោតលើសំឡេង។*

**៣**

***រៀនអានពាក្យ៖***
*ឃ្លាដំបូងៗ ជាមួយពាក្យច្រំដែលច្រើនៗ កុមារចាប់ផ្តើមចូលរួមជាមួយការអានឮៗ។ កុមារចាប់ផ្តើមផ្គូរផ្គងសំឡេង និងពាក្យ។*

## ៥. ការបែងចែកតាមចំណាប់ចំណូលចិត្ត

ចំណូលចិត្តរបស់កុមារទូទៅមិនដូចគ្នាទេ។ ឧទាហរណ៍ គេច្រើនសម្គាល់ឃើញថា កុមារីចូលចិត្តរឿងបែបទន់ភ្លន់ មានតួអង្គព្រះនាង កុមារាចូលចិត្តរឿងមានការប្រយុទ្ធគ្នា ឬសៀវភៅបែបវិទ្យាសាស្ត្រ។ ដូច្នេះការផលិតសៀវភៅត្រូវតែមានភាពសំបូរបែប ដើម្បីឱ្យកុមារមានជម្រើសច្រើនក្នុងការអាន។ សាច់រឿងក៏ត្រូវសមស្របទៅតាមវប្បធម៌នៃប្រទេសដែលពួកគេរស់នៅដែរ។



# ការផលិតសៀវភៅកុមារតូច



ដើម្បីឱ្យសៀវភៅមួយចេញជារូបរាង យើងត្រូវគិត និងវិភាគគ្រប់ជ្រុងជ្រោយ ទាំងអត្ថបទ និងរូបភាព។

## ១. ការនិពន្ធ



ដើម្បីមានគំនិតក្នុងការនិពន្ធសៀវភៅសម្រាប់កុមារតូច យើងត្រូវចំណាយពេលស្វែងយល់ពីកុមារតូច ពីការអភិវឌ្ឍតាមតំណាក់កាលអាយុរបស់ពួកគេ ក៏ដូចជាការស្វែងយល់ពីលក្ខណៈរបស់សៀវភៅកុមារតូចដូចដែលបានរៀបរាប់ខាងលើ។ ការតែងនិពន្ធរឿងត្រូវគិតពីការជ្រើសរើសតួអង្គដែលអាចជាកុមារតូច ជាសត្វ ឬវត្ថុផ្សេងៗដែលកុមារតូចស្គាល់។ ប្រធានបទសាមញ្ញពាក់ព័ន្ធនឹងជីវិតរស់នៅរបស់ពួកគេ។

## ២. ការបង្កើតរូបភាព



រូបភាព និងអត្ថបទត្រូវឱ្យមានទំនាក់ទំនងគ្នា។ ភាគច្រើនរូបភាពសម្រាប់សៀវភៅកុមារតូចត្រូវមានគំនូសគ្រេតច្បាស់ និងពណ៌ដិត។ យើងត្រូវសិក្សាពីប្លង់ទំព័រ ដើម្បីកុំឱ្យដាច់រូបភាព ឬរូបភាពសំខាន់នៅចំកណ្ដាលទំព័រដាច់។ ជៀសវាងការប្រើប្លង់រូបមើលពីឆ្ងាយ ឬមើលពីលើ។ កុមារតូចមិនទាន់ដឹងថារូបដែលនៅឆ្ងាយមើលឃើញតូច ឬរូបនៅជិតមើលឃើញធំនៅឡើយទេ។

## ៣. ការបោះពុម្ព

*សៀវភៅដែលរួចរាល់សម្រាប់ការបោះពុម្ព ត្រូវមានលេខISBN ដែលយើងអាចស្នើសុំពីបណ្ណាល័យជាតិ។ មុនការបោះពុម្ព គួរឆ្លងកាត់គណៈកម្មការអំណានដើម្បីជៀសវាងកំហុសផ្សេងៗដូចជា អក្ខរាវិរុទ្ធ ភាពមិនសមហេតុផលនៃសាច់រឿង ឬរូបគំនូរ។ វាជាការសំខាន់ដែលត្រូវមានការធ្វើតេស្តសៀវភៅជាមួយក្រុមអំណានគោលដៅដើម្បីកែលម្អសៀវភៅឱ្យបានប្រសើរមុននឹងបោះពុម្ព។ យើងត្រូវពិនិត្យមើលតម្លៃ និងគុណភាពដែលផ្តល់ឱ្យពីរោងពុម្ពផ្សេងៗ មុននឹងសម្រេចចិត្តរើសយករោងពុម្ពណាមួយ។*



*ការសរសេរអត្ថបទ*



*ការកែប្លង់រូបភាព*



*ការរចនាទំព័រលើកុំព្យូទ័រ*



*ការធ្វើកំណែអត្ថបទជាក្រុម*

## ៤. ការធ្វើសៀវភៅដោយដៃ

សៀវភៅកុមារតូចក៏អាចធ្វើដោយដៃបានដែរ ដោយប្រើប្រាស់សម្ភារៈមួយចំនួនដូចជា ក្រដាសកាតុង ក្រណាត់ ពណ៌ផាត់ ក្រដាសពណ៌ កាវ កន្ត្រៃ កង... នៅតាមសាលាមត្តេយ្យ គ្រូត្រូវបានលើកទឹកចិត្តឱ្យផលិតសៀវភៅជាមួយកុមារដើម្បីឱ្យពួកគេបានចូលរួមសកម្មភាព ច្នៃប្រឌិតនានា។ ឪពុកម្តាយ ឬអ្នកមើលថែកុមារតូចក៏អាចផលិតសៀវភៅងាយៗសម្រាប់ប្រើប្រាស់បានដែរ។



ការគូររូប



ការកាត់រូប



ការបិទក្រដាសពណ៌



ការបិទផ្ទៃរូប(texture)

# ការងារផ្សេងៗលើវិស័យសៀវភៅ



*គួរស្វែងយល់ពីការងារផ្សេងៗលើវិស័យសៀវភៅដើម្បីយល់ដឹងឱ្យបានច្បាស់ពីចំនុចសំខាន់ផ្សេងទៀតក្នុងការផលិតសៀវភៅ។*

## ១. តួនាទីអ្នកធ្វើការលើវិស័យសៀវភៅ

- *អ្នកបោះពុម្ពផ្សាយ ៖ ជាអ្នកសិក្សាទីផ្សារដើម្បីដឹងថាសៀវភៅដែលនឹងផលិតឆ្លើយតបនឹងទីផ្សារបង្កើតក្រុមសៀវភៅ ស្វែងរកអ្នកនិពន្ធ អ្នកគំនូរ ដែលស័ក្តិសមនឹងគម្រោង។ ជាអ្នកទទួលខុសត្រូវរួមលើគម្រោង (ថវិកា ផែនការ កិច្ចសន្យា ការបញ្ជាបោះពុម្ព...)។*

- *អ្នកនិពន្ធ ៖ ជាអ្នកស្រាវជ្រាវ ប្រមូលព័ត៌មាន ធ្វើបច្ចុប្បន្នភាពព័ត៌មាន បង្កើតគំនិតនិពន្ធថ្មី សរសេរអត្ថបទ ឬរឿង កែសម្រួលតាមមតិយោបល់របស់អ្នកបោះពុម្ពផ្សាយ តម្រូវតាមកម្រិត និងចំណង់ចំណូលចិត្តរបស់អ្នកអានតាមសម័យកាល។*

- *អ្នករៀបរៀង ៖ ជាអ្នកចងក្រងអត្ថបទដែលមានស្រាប់ដោយសរសេរឡើងវិញតម្រូវតាមកម្រិតអាយុអ្នកអាន។*

- *អ្នកបកប្រែ ៖ ជាអ្នកបកប្រែអត្ថបទពីភាសាបរទេសមកជាភាសាកំណើតដោយគោរពតាមគំនិតរបស់អ្នកនិពន្ធ។*

- *អ្នកគំនូរ ៖ ជាអ្នកបង្កើតគោលគំនិតរូបភាពតាមរយៈសាច់រឿង កែសម្រួលតាមមតិយោបល់របស់អ្នកទទួលខុសត្រូវសិល្បៈរូបភាព បង្កើតគំនិតគូរថ្មី តម្រូវតាមកម្រិត និងចំណង់ចំណូលចិត្តរបស់អ្នកអានតាមសម័យកាល។*

- ✔ អ្នករចនាទំព័រ ៖ ជាអ្នកបញ្ចូលអត្ថបទ និងរូបភាពឱ្យត្រូវតាមទម្រង់ខ្នាតរបស់ក្រុមសៀវភៅ និងជាអ្នកបង្កើតសោភ័ណភាពសៀវភៅ។

- ✔ អ្នកទទួលខុសត្រូវសិល្បៈរូបភាព ៖ ជាអ្នកបង្កើតគោលគំនិតនៃក្រុមសៀវភៅ (រូបរាង កម្រាស់ ទំហំ សម្ភារៈប្រើប្រាស់សម្រាប់ការផលិត) និងជាអ្នកទទួលខុសត្រូវគុណភាពរូបភាព ទំនាក់ទំនងរវាងអត្ថបទនិងរូបភាព ព្រមទាំងជាអ្នកជ្រើសរើសពណ៌ឱ្យសមតាមសាច់រឿង។

- ✔ អ្នកត្រួតពិនិត្យអត្ថបទ ៖ ជាអ្នកពិនិត្យគុណភាពអត្ថបទឱ្យសមស្របទៅនឹងកម្រិតអ្នកអាន (អក្ខរាវិរុទ្ធ ឃ្លាឃ្លោង ខណ្ឌសញ្ញា វេយ្យាករណ៍។ល។)

- ✔ អ្នកទទួលខុសត្រូវបច្ចេកទេសបោះពុម្ព ៖ ជាអ្នកស្គាល់បច្ចេកទេសរោងពុម្ព ធ្វើការជាមួយរោងពុម្ព (ជ្រើសរើសសម្ភារៈដើម្បីចំណាយតិចគុណភាពល្អ) អ្នកពិនិត្យពណ៌នៅរោងពុម្ព។

- ✔ អ្នកឯកទេសបោះពុម្ព ៖ ជាអ្នកមានបច្ចេកទេសក្នុងការបញ្ជាម៉ាស៊ីនបោះពុម្ព ធានាគុណភាពទៅតាមការចង់បានរបស់អ្នកបោះពុម្ពផ្សាយ។

- ✔ អ្នកចែកចាយ ៖ ជាអ្នកទទួលខុសត្រូវពាណិជ្ជកម្ម ការផ្សព្វផ្សាយ ការស្វែងរកទីផ្សារ ការដឹកជញ្ជូន ការគ្រប់គ្រងស្តុក និងចំណូល។

### កំណត់សម្គាល់

សម្រាប់ការផលិតសៀវភៅកុមារតូច តួនាទីខាងលើអាចមានការផ្លាស់ប្តូរ។

ឧទាហរណ៍៖

- ✔ អ្នកបោះពុម្ពផ្សាយអាចសរសេរអត្ថបទដូចអ្នកនិពន្ធ អាចជាអ្នកត្រួតពិនិត្យអត្ថបទ ឬ/និងជាអ្នកទទួលខុសត្រូវសិល្បៈរូបភាព។
- ✔ អ្នកគំនូរអាចជាអ្នកនិពន្ធបើអត្ថបទតិច។
- ✔ អ្នកនិពន្ធអាចជាអ្នកស្វែងរកគោលគំនិតរូបភាព។ល។



## ២. ទំនាក់ទំនងរវាងអ្នកបោះពុម្ពផ្សាយ អ្នកនិពន្ធ អ្នកគំនូរ

កិច្ចសន្យាអ្នកនិពន្ធ និងអ្នកគំនូរត្រូវមានលក្ខខណ្ឌដូចខាងក្រោមៈ

- ✔ តម្លៃ ៖ កម្រៃប្រាក់ការងារដែលបានពីការគណនាចំនួនអត្ថបទ(សម្រាប់អ្នកនិពន្ធ) និងចំនួនរូប(សម្រាប់អ្នកគំនូរ) ដោយផ្អែកលើតម្លៃដែលព្រមព្រៀងដោយភាគីទាំងសងខាង។
- ✔ តួនាទី ៖ អ្នកនិពន្ធ និងអ្នកគំនូរត្រូវយល់ព្រមកែសម្រួលអត្ថបទ ឬរូបភាពតាមការស្នើរបស់អ្នកបោះពុម្ពផ្សាយ ដោយផ្អែកលើអំណះអំណាងសមស្រប។
- ✔ ពេលវេលា ៖ ការកំណត់ពេលវេលាត្រូវធ្វើឡើងដោយមានការព្រមព្រៀងរវាងភាគីទាំងសងខាង មុននឹងចុះកិច្ចសន្យា។ ភាគីទាំងអស់ត្រូវគោរពទៅតាមពេលវេលាកំណត់ដើម្បីឱ្យការបោះពុម្ពសៀវភៅចេញតាមកាលបរិច្ឆេទដែលបានកំណត់។
- ✔ បច្ចេកទេស ៖ ភាគច្រើនសម្រាប់អ្នកគំនូរ ការកំណត់បច្ចេកទេសដាក់ពណ៌ (គំនូរដោយដៃ ឬដោយកុំព្យូទ័រ) ត្រូវធ្វើឡើងនៅក្នុងដំណាក់កាលពេលចរចាលើកិច្ចសន្យា។
- ✔ កម្មសិទ្ធិបញ្ញា ៖ ភាគីទាំងសងខាងមិនអាចបំពានដោយប្រើប្រាស់ស្នាដៃដែលបានកំណត់ក្នុងកិច្ចសន្យាដូចជាការបោះពុម្ពលើសចំនួន ការយកទៅប្រើប្រាស់ក្នុងរូបភាព ឬភាសាផ្សេង។
- ✔ ចំនួនសៀវភៅត្រូវបោះពុម្ព និងចំនួនសៀវភៅផ្តល់ជូនដោយឥតគិតថ្លៃត្រូវមានបញ្ជាក់ក្នុងកិច្ចសន្យា។

## ៣. ការធ្វើតេស្ត

ការធ្វើតេស្តមានតួនាទីដើម្បីផ្ទៀងផ្ទាត់ថា តើសៀវភៅដែលនឹងបោះពុម្ពឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់អ្នកអានឬទេ។ ដើម្បីធ្វើតេស្ត យើងត្រូវ ៖

- ✔ រកក្រុមគោលដៅ(អ្នកប្រើប្រាស់សៀវភៅ គ្រូនិងសិស្ស ឪពុកម្តាយនិងកូន អ្នកមើលថែនិងកុមារតូច)
- ✔ សៀវភៅគំរូត្រូវដូចសៀវភៅគ្រោងផលិតយ៉ាងតិចបំផុត ៨០%
- ✔ ត្រៀមសំណួរមួយចំនួន ជៀសវាងការភ្លេច
- ✔ រៀនសង្កេតប្រតិកម្មឆ្លើយតបរបស់អ្នកអាន កត់ត្រា និងចេះរកដំណោះស្រាយ។

## របៀបធ្វើតេស្ត

ដើម្បីបានលទ្ធផល យើងអាចប្រើវិធីសាស្ត្រសំណួរមិនផ្ទាល់ ដូចជា ផ្តល់ជម្រើស និងឱ្យគេអាន ឬប្រើផ្ទាល់។ ខាងក្រោមជាវិធីសាស្ត្រមួយចំនួន ៖

សំណេះសំណាល ៖ ជាដំណាក់កាលដំបូងដើម្បីណែនាំខ្លួន ពន្យល់ពីគោលបំណង និងស្គាល់អ្នកចូលរួម។
ឧទាហរណ៍ សំណួរមួយចំនួនដូចជា ៖ ជម្រាបសួរ! សុខសប្បាយជាទេពូមីង? មានកូនប៉ុន្មាននាក់? មានអាយុប៉ុន្មាន? ចូលរៀនឬនៅ? ធ្លាប់អានសៀវភៅឱ្យកូនស្តាប់ឬទេ? ពួកយើងជាអ្នកផលិតសៀវភៅ បាននាំយករឿងថ្មីមកសុំមតិយោបល់ពីពូមីង ដើម្បីឱ្យសៀវភៅរឹតតែប្រសើរ...
តាមរយៈចម្លើយយើងអាចដឹងពីស្ថានភាពរបស់អ្នកចូលរួម ជាពិសេសទាក់ទងនឹងការប្រើប្រាស់សៀវភៅ។ វាក៏អាចជួយយើងបង្កើនទំនុកចិត្ត និងភាពស្និទ្ធស្នាលដើម្បីទទួលបានការកែលម្អយ៉ាងសុក្រឹតពីអ្នកចូលរួម។

សង្កេត ៖ ចែកសៀវភៅជូនអ្នកចូលរួមដើម្បីអានតាមក្រុម(ចម្រុះមនុស្សធំ និងកុមារតូច)។ ដើម្បីចង់ដឹងថាអត្ថបទសមស្របនឹងសមត្ថភាពអានរបស់ពួកគាត់ឬទេ យើងអាចសុំឱ្យសមាជិកម្នាក់អានឮៗ។ ពេលនោះយើងដឹងថាអ្នកអានអាចអានបានឬទេ អ្នកស្តាប់ចាប់អារម្មណ៍ឬទេ។

*សំណួរផ្ទៀងផ្ទាត់ ៖ ដើម្បីដឹងពីចំណាប់អារម្មណ៍របស់អ្នកអានយើងអាចសួរសំណួរទាក់ទងនឹងសៀវភៅ ដូចជាចំណងជើង ឈ្មោះតួអង្គ សកម្មភាពតួអង្គ... ជៀសវាងសំណួរត្រង់ៗដូចជា តើពូមីងចូលចិត្តឬមិនចូលចិត្ត? រូបស្អាតឬមិនស្អាត? អត្ថបទស្រួលអានឬមិនស្រួលអាន?...*

*ដំណោះស្រាយ ៖ កត់ត្រាគ្រប់សកម្មភាពអ្នកចូលរួម (ទឹកមុខ កាយវិការ ពាក្យសំដី ឥរិយាបថ ភាពរលូននៃការអាន...) បន្ទាប់មកយើងស្វែងយល់ពីចំណុចដែលត្រូវកែប្រែៗ ឧទាហរណ៍ បើពួកគាត់អានទាក់ៗ គួរសម្រួលអត្ថបទៗ បើរូបមិនច្បាស់ គួរកែសម្រួលរូបៗ បើអត្ថបទ និងរូបភាពមិនស្របគ្នា គួរកែសម្រួលម៉ាកែតសៀវភៅឡើងវិញៗ*

## ៤. ការគ្រប់គ្រងលើចំណាយ

*ការផលិតសៀវភៅទាមទារចាំបាច់ដើមទុនខ្លះសម្រាប់ធ្វើការបោះពុម្ព ក៏ដូចជាការទ្រទ្រង់ចំណាយផ្សេងៗ។*

*ចំណាយមានពីរប្រភេទគឺ ៖*
***ថ្លៃដើមផ្ទាល់*** *៖ អ្នកនិពន្ធ អ្នកគំនូរ អ្នកបកប្រែ អ្នកត្រួតពិនិត្យអត្ថបទ អ្នកថតរូប ថ្លៃបោះពុម្ព។ល។*
***ថ្លៃដើមមិនផ្ទាល់*** *៖ ប្រាក់ខែបុគ្គលិក ចំណាយលើការធ្វើតេស្ត ថ្លៃផ្ទះ ថ្លៃទឹកភ្លើង សំរាម ពន្ធដារ ពន្ធអាជីវកម្ម អ៊ីនធឺណែត ទូរស័ព្ទ ថ្លៃដឹកជញ្ជូន ប្រាក់កម្រៃជើងសារ។ល។*

**របៀបគណនាតម្លៃលក់**

*ការកំណត់ថ្លៃលក់សៀវភៅមួយក្បាល* = $\frac{\text{(ថ្លៃដើមផ្ទាល់ + ថ្លៃដើមមិនផ្ទាល់)}}{\text{(ចំនួនសៀវភៅបោះពុម្ពសរុប)}}$ + *ប្រាក់ចំណេញ (តាមលទ្ធភាពទីផ្សារ)*

## ៥. ការចែកចាយ និងការគ្រប់គ្រងស្តុក

*ការចែកចាយ និងការគ្រប់គ្រងតម្រូវឱ្យមានជំនាញច្បាស់លាស់ដើម្បី ៖*

- ✔ *ស្គាល់ទីផ្សារគ្រប់តំបន់*
- ✔ *សេវាកម្មល្អ (ការដឹកជញ្ជូនរហ័សទាន់ចិត្ត និងឥតគិតថ្លៃ)*
- ✔ *គ្រប់គ្រង និងផែកស្តុកតាមទីផ្សារជាប្រចាំ*
- ✔ *ធ្វើបច្ចុប្បន្នភាពទីផ្សារ(តាំងពិព័រណ៍សៀវភៅ ទិវាសៀវភៅកុមារ... )*
- ✔ *ធ្វើការផ្សព្វផ្សាយ*
- ✔ *ការប្រមូលថវិកា និងធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំឆ្នាំ*

**កំណត់សម្គាល់**

**ត្រូវប្រុងប្រយ័ត្នក្នុងការទុកដាក់សៀវភៅក្នុងស្តុក ជៀសវាងកត្តាដែលធ្វើឱ្យសៀវភៅឆាប់ខូច ដូចជាសំណើម ទឹកលិច កម្តៅ ឬសត្វផ្សេងៗមកកាត់បំផ្លាញ។**

# ៦. ជីវិតថ្មីរបស់សៀវភៅ

ស្នាដៃសៀវភៅល្អៗជុំវិញពិភពលោក ត្រូវបានគេយកទៅបន្តការផលិតតាមរូបភាពផ្សេងទៀតដូចជា ៖

- ការយកលំនាំតាម (ផលិតគំនូរជីវចល ផលិតភាពយន្ត សម្តែងឈុតឆាក...)
- សៀវភៅអេឡិចត្រូនិច (E-book)
- លក់សិទ្ធិបកប្រែ
- ។ល។














គណៈកម្មការនិពន្ធ ៖  កុល សៀប, ខូយ រ៉ានី, គីមស៊ុន សុធារី, ងួន សាកល, ឆាយ ផល្លី,
ញ៉ែម សូម៉ាលី, ទ្រី សម្ផស្ស, ពេជ ព្រឿង, ព្រហ្ម ពុធវិសាល, ព្រុំ គន្ធារ៉ូ,
ព្រំ វិចិត្រ, ភូ ចរិយា, វន វ៉ាន់ថា, សុខ រ៉ាលីន, សុត សុជាតា, សេង វិសាល,
សេង វិសុទ្ធ, ស្រី ប៊ុនលី, ហួត សុជាតា, ហួន សុធារ័ត្ន និង ឡាច ផារី។

អ្នកគំនូរ ៖ សេង វិសុទ្ធ

អ្នករចនាទំព័រ ៖ គ្រេង បញ្ញា

© គ្រឹះស្ថានបោះពុម្ពផ្សាយSipar 2015

ផ្ទះលេខ9 ផ្លូវ21 ប្រអប់សំបុត្រ31 ភ្នំពេញ កម្ពុជា
ទូរស័ព្ទ ៖ 855-23-216 001 / edition@sipar-cam.org / www.sipar-books.com

រាល់ការចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ទោះបីជាតាមរបៀបណាក៏ដោយ
បើគ្មានការយល់ព្រមពីអង្គការSipar គឺខុសច្បាប់ និងត្រូវមានទោស។
រក្សាសិទ្ធិចម្លង និងបកប្រែចំពោះគ្រប់ប្រទេសទាំងអស់។

បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពSok  Heng Printing House